Nº 6

# រូបភាព និងសម្ភារៈឃោសនាផ្សព្វផ្សាយ

**សំណួរៈ** **ក្នុងដំណាក់កាលឃោសនាបោះឆ្នោត តើមធ្យោបាយបែបណា ដែលគណបក្សនយោបាយ បេក្ខជន និងអ្នកគាំទ្រអាចយកមកប្រើប្រាស់បាន ?**

**ចម្លើយៈ** គណបក្សនយោបាយ បេក្ខជនឈរឈ្មោះបោះឆ្នោត និងអ្នកគាំទ្រទាំងឡាយ អាចប្រើប្រាស់រូបភាព ឬសម្ភារៈនិងមធ្យោបាយឃោសនាផ្សព្វផ្សាយបានដូចជា÷

-ខិត្តប័ណ្ណឃោសនាបោះឆ្នោត ។

-សារព័ត៌មាន (ការផ្សព្វផ្សាយ គំនូរជីវចល ការជូនព័ត៌មាន សេចក្តីថ្លែងការណ៍ សារនយោបាយ រូបសញ្ញាគណបក្ស)។

-ការឃោសនាតាមវិទ្យុ ទូរទស្សន៍ ឬតាមឧត្ទេសនស័ព្ទ ឬឧបករណ៍បញ្ចាំងរូបភាព ។

**សំណួរៈ** **សម្ភារៈសម្រាប់ឃោសនាតាមវិទ្យុ ទូរទស្សន៍ ឬឧបករណ៍បញ្ចាំងរូបភាព មានអ្វីខ្លះ?**

**ចម្លើយៈ** សម្ភារៈទាំងនោះមានដូចជា÷

-អត្ថបទឃោសនា ។

-បទភ្លេង និងចម្រៀង ។

-ពាក្យស្លោកខ្លីៗ ។

-ការសូត្រពាក្យកំណាព្យ ។

-ការប្រគំតន្ត្រី ។

-កិច្ចសម្ភាសន៍ដោយបន្តផ្ទាល់ ឬដោយការចាក់ផ្សាយ ។

-ការសម្តែងសិល្បៈ ។

-ការចាក់កាសែត្សវីដេអូជាសាធារណៈ ។

**សំណួរៈ** **តើនៅមានរូបភាពអ្វីផ្សេងទៀតទេ ដែលអាចប្រើប្រាស់បានសម្រាប់ការឃោសនាផ្សព្វផ្សាយនេះ ?**

**ចម្លើយៈ** ក្រៅពីរូបភាព និងសម្ភារៈឃោសនាបោះឆ្នោត ដូចដែលបានរៀបរាប់ខាងលើ នៅមានរូបភាពផ្សេងៗ ជាច្រើនទៀតដែលអាចប្រើប្រាស់បានក្នុងការឃោសនាផ្សព្វផ្សាយដូចជា÷(ប.ន ៧.១៤.៤)

-ការសម្តែងរឿងល្ខោនខ្លីៗ ឬ/និង សិល្បៈ ឬការបញ្ចាំងខ្សែភាពយន្ត ឬ/និងវីដេអូ។

-ការបង្ហោះប៉េងប៉ោង ឬ/និងខ្លែង ។

-ការបោះពុម្ពជារូបភាពសម្រាប់បិទផ្សាយលើសំលៀកបំពាក់ មួក ស្លាកសញ្ញា ពាក្យស្លោក ឬរូបភាពបិទតាមរថយន្ត ស្លាកសញ្ញាលោហៈខ្នាស់ បដា ។ល។

-ការស្រែកឃោសនា តាមទីសាធារណៈ ។

**សំណួរៈ** **ពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ តើគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវបានអនុញ្ញាតឱ្យជួលប្រព័ន្ធផ្សព្វផ្សាយឯកជនបានដែរឬទេ ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ?**

**ចម្លើយៈ** គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវបានអនុញ្ញាតឱ្យចំណាយទៅលើការជួលផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ និងការបោះពុម្ពផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយឯកជន នៅក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។ (ប.ន ៧.១៤.៥.១)

**សំណួរៈ** **តើប្រព័ន្ធផ្សព្វផ្សាយឯកជនត្រូវលៃលកយ៉ាងណា សម្រាប់គណបក្សនយោបាយដែលជួលនោះ ?**

**ចម្លើយៈ** ប្រព័ន្ធផ្សព្វផ្សាយឯកជន ដែលមានបំណងទទួលយកការជួលផ្សាយរបស់គណបក្សនយោបាយ ត្រូវលៃលកទុកពេលវេលា និងម៉ោងផ្សាយ ដើម្បីផ្តល់ជូនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតទាំងអស់ជួលផ្សព្វផ្សាយដូចគ្នា ដោយឈរលើមូលដ្ឋាន ឱកាសនិងតម្លៃស្មើភាពគ្នា។ (ប.ន.៧.១៤.៥.២)

**សំណួរៈ** **បើអញ្ចឹង ប្រព័ន្ធផ្សព្វផ្សាយឯកជនចាំបាច់ត្រូវទទួលការជួលផ្សព្វផ្សាយរបស់គណបក្សនយោបាយមែនទេ ?**

**ចម្លើយៈ** មិនមែនយ៉ាងដូច្នោះទេ ប្រព័ន្ធផ្សព្វផ្សាយឯកជនអាចមិនចុះផ្សាយ ឬមិនលក់ម៉ោងផ្សព្វផ្សាយទៅឱ្យគណបក្សនយោបាយ ក្នុងអំឡុងពេលឃោសនាបោះឆ្នោតបាន ។ ប្រសិនបើប្រព័ន្ធផ្សព្វផ្សាយឯកជនណាមួយ សម្រេចមិនចុះផ្សាយ ឬមិនលក់ម៉ោងផ្សព្វផ្សាយ ទៅគណបក្សណាមួយ ប្រព័ន្ធផ្សព្វផ្សាយនោះត្រូវបដិសេធការជួលផ្សព្វផ្សាយ និងចុះផ្សាយរបស់គណបក្សនយោបាយទាំងអស់ ។ (ប.ន.៧.១៤.៥.៣)

**សំណួរៈ** **ចំពោះកម្មវិធីផ្សព្វផ្សាយដែលអនុវត្តតាមគោលការណ៍ស្មើភាពនោះ មានអ្វីខ្លះ ?**

**ចម្លើយៈ** ចំពោះកម្មវិធីផ្សព្វផ្សាយដែលត្រូវអនុវត្តតាមគោលការណ៍ស្មើភាព មានដូចជា ÷

-ការចាក់ផ្សាយស្ប៉តរបស់គណបក្សនយោបាយ តាមរយៈវិទ្យុ និងទូរទស្សន៍របស់រដ្ឋ។

-ការចាក់ផ្សាយកិច្ចពិភាក្សាតុមូល សម្រាប់គណបក្សនយោបាយ តាមរយៈវិទ្យុ និងទូរទស្សន៍របស់រដ្ឋ ។

-ការចុះផ្សាយអត្ថបទឃោសនា អំពីគោលនយោបាយ និងកម្មវិធីនយោបាយ ឬសាររបស់គណបក្សនយោបាយ ឬប្រសាសន៍ដើមទាំងស្រុងរបស់ប្រធានគណបក្ស ឬបេក្ខជនឈរឈ្មោះបោះឆ្នោត លើព្រឹត្តិបត្ររបស់ គ.ជ.ប ។ ( ប.ន.៧.១៤.៦.៦)

**សំណួរ:** **សម្ភារៈអប់រំអ្នកបោះឆ្នោត និងសម្ភារៈឃោសនាដែលត្រូវបានផ្សព្វផ្សាយ តើមានទម្រង់បែបណា ?**

**ចម្លើយ:** សម្ភារៈអប់រំអ្នកបោះឆ្នោត និងសម្ភារៈឃោសនាដែលត្រូវបានផ្សព្វផ្សាយជាទម្រង់ អត្ថបទបោះពុម្ព ឬផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ តែមិនត្រូវប្រើប្រាស់រូបភាព ឬភាសាណាមួយដែលមានន័យ ÷( ប.ន.៧.១៤.៩)

-ញុះញង់អ្នកបោះឆ្នោតឱ្យប្រើអំពើហិង្សា បំភិតបំភ័យ គំរាមកំហែងប្រឆាំងអ្នកបោះឆ្នោត ឬគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬធ្វើឱ្យបាត់បង់ជំនឿលើភាពសម្ងាត់នៃការបោះឆ្នោត ។

-មាក់ងាយ បំភិតបំភ័យ ប្រមាថ ឬអសីលធម៌ ។

-សាបព្រោះភាពភ័យខ្លាច ធ្វើឱ្យភ័ន្តច្រឡំ និងខូចសណ្តាប់ធ្នាប់សង្គម ។

-ផ្តល់ព័ត៌មានមិនត្រឹមត្រូវអំពីដំណើរការបោះឆ្នោត ។

**សំណួរ:** **មុននឹងធ្វើការផ្សព្វផ្សាយ តើសម្ភារៈផ្សព្វផ្សាយទាំងអស់ត្រូវត្រួតពិនិត្យដោយគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាពទេ ?**

**ចម្លើយ:** សម្ភារៈផ្សព្វផ្សាយមួយចំនួន ត្រូវបានត្រួតពិនិត្យអំពីភាពត្រឹមត្រូវតាមលក្ខខណ្ឌដូចដែលបានរៀបរាប់ខាងលើ ដោយគណៈកម្មការសម្របសម្រួលកម្មវិធីស្មើភាព មុននឹងធ្វើការផ្សព្វផ្សាយដូចជា ÷

-សម្ភារៈផ្សព្វផ្សាយផលិតដោយ គ.ជ.ប ។

-សម្ភារៈផ្សព្វផ្សាយផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិ ដែលសហការជាមួយ គ.ជ.ប ។

-សម្ភារៈឃោសនារបស់គណបក្សនយោបាយ ក្នុងកម្មវិធីស្មើភាព ។( ប.ន.៧.១៤.៦.៧)

ប៉ុន្តែសម្ភារៈឃោសនារបស់គណបក្សនយោបាយដែលមិនពាក់ព័ន្ធនឹងកម្មវិធីស្មើភាព និងសម្ភារៈអប់រំអ្នកបោះឆ្នោត ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាល មិនត្រូវបានត្រួតពិនិត្យដោយ គ.ជ.ប ទេ ។ តែសម្ភារៈឃោសនាទាំងនេះ ត្រូវគោរពតាមលក្ខខណ្ឌដូច កំណត់ខាងលើ ។ (ប.ន.៧.១៤.៦.៨)

ដូច្នេះការផ្សព្វផ្សាយ ការចុះផ្សាយ ឬការបោះពុម្ពផ្សាយសម្ភារៈអប់រំអ្នកបោះឆ្នោត និងសម្ភារៈឃោសនា ដែលត្រូវបានរកឃើញថា រំលោភបញ្ញត្តិខាងលើ គ.ជ.ប អាចបញ្ជាឱ្យដកហូត ឬបញ្ឈប់ការផ្សព្វផ្សាយ និងការប្រើប្រាស់សម្ភារៈខុសច្បាប់ទាំងនោះ ។(ប.ន.៧.១៤.១០)

គណបក្សនយោបាយ ឬអង្គការសាមី ត្រូវទទួលខុសត្រូវចំពោះសម្ភារៈអប់រំ និងសម្ភារៈឃោសនាដែលខ្លួនផ្សព្វផ្សាយ និងត្រូវទទួលទោសតាម ច.ប.ត.រ ប្រសិនបើសម្ភារៈទាំងនោះ រំលោភលើលក្ខខណ្ឌខាងលើ ។(ប.ន.៧.១៤.១១)

**សំណួរ:** **គ្រប់សម្ភារៈឯកសារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយទាំងអស់ មានអ្វីជាសម្គាល់ដែរទេ ?**

**ចម្លើយ:** គ្រប់សម្ភារៈឯកសារឃោសនាបោះឆ្នោតទាំងអស់ដែលបានបោះពុម្ព ចែកផ្សាយ ឬផ្សព្វផ្សាយដោយបេក្ខជន ឬ/និងគណបក្សនយោបាយ ត្រូវតែមានដាក់សញ្ញាសម្គាល់ ឈ្មោះ ឬ/និងអាសយដ្ឋានរបស់សាមីគណកប្សនយោបាយនោះ ។(ប.ន.៧.១៤.៨)

**សំណួរ:** **ក្នុងសកម្មភាពឃោសនារកសម្លេងឆ្នោត តើគណបក្សនយោបាយ និងបេក្ខជន ត្រូវចៀសវាងអ្វីខ្លះ ?**

**ចម្លើយ:** -ហាមធ្វើសកម្មភាពឃោសនាដោយយកព្រះឆាយាល័ក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារ ស្នាព្រះហស្ត និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រីព្រះវររាជមាតា និងរូបសញ្ញា គ.ជ.ប ទៅប្រើប្រាស់ ដើម្បីរកសម្លេងឆ្នោត ។(ប.ន.៧.១៤.១២)

-ហាមលើកបដាឃោសនា ស្លាកសញ្ញាគណបក្ស និងរូបសញ្ញាណាមួយ ដែលបង្ហាញពីការគាំទ្រគណបក្សនយោបាយណាមួយឬបេក្ខជនណាម្នាក់កាត់ទទឹងផ្លូវសាធារណៈ ។(ប.ន.៧.១៤.១៣)

**សំណួរ:** **ទាក់ទងនឹងការសុំជួលទីតាំងសម្រាប់ប្រើប្រាស់ក្នុងការឃោសនា តើគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវធ្វើដូចម្តេច ?**

**ចម្លើយ:** គណបក្សនយោបាយ ឬ/និងបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលមានបំណងជួលទីតាំង អាចដាក់ពាក្យសុំទៅអ្នកគ្រប់គ្រងទីកន្លែងទាំងនោះ ក្នុងរយៈពេលយ៉ាងតិច ០៣ថ្ងៃ មុនថ្ងៃប្រជុំឃោសនាបោះឆ្នោតរបស់ខ្លួន ។ (ប.ន.៧.១៥)

**សំណួរ:** **តើអ្នកគ្រប់គ្រងទីតាំងជួលនោះ ត្រូវធ្វើដូចម្ដេចដែរ ?**

**ចម្លើយ:** អ្នកគ្រប់គ្រងទីតាំងជួល ដូចជា រោងមហោស្រព មណ្ឌលកីឡា ឧទ្យាន សាធារណៈ ឬសាលសាធារណៈ ត្រូវផ្ដល់ទីកន្លែងរបស់ខ្លួនដល់គណបក្សនយោបាយ ឬ/និង បេក្ខជនឈរឈ្មោះបោះឆ្នោតដែលសុំជួលប្រើប្រាស់ជាកន្លែងឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់មុនក្រោយនៃការស្នើសុំ ។ ហើយអ្នកគ្រប់គ្រងទីកន្លែងទាំងនោះ ត្រូវឆ្លើយតបទៅនឹងការស្នើសុំរបស់គណបក្សនយោបាយមិនឱ្យលើសពី ២៤ម៉ោង ក្រោយពីបានទទួលពាក្យស្នើសុំ ។ (ប.ន.៧.១៥)

ក្នុងករណីដែលអ្នកគ្រប់គ្រងទីកន្លែងទាំងនោះ មិនបានឆ្លើយតបទៅនឹងការស្នើសុំរបស់គណបក្សនយោបាយក្នុងរយៈពេល ២៤ម៉ោងទេ ចាត់ទុកថា ជននោះប្រព្រឹត្តល្មើសនឹងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ជននោះនឹងត្រូវទទួលការព្រមាន ហើយក្នុងករណីមិនព្រមអនុវត្តតាម ត្រូវលុបឈ្មោះពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ៥ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីការដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់បណ្ដេញចេញពីមុខតំណែង និងត្រូវផ្ដន្ទាទោស ពិន័យជាប្រាក់ពី ១លាន ដល់ ២លានរៀល ។

**សំណួរ:** **ចំពោះទីកន្លែងឯកជន តើគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត អាចធ្វើសកម្មភាពឃោសនាបានឬទេ ?**

**ចម្លើយ:** គណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត អាចធ្វើសកម្មភាពឃោសនានៅលើទីកន្លែងឯកជន ឬនៅសាលឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គខ/កប ឬ/និង គឃ/សប យ៉ាងតិច ០៣ថ្ងៃ មុនថ្ងៃធ្វើសកម្មភាពឃោសនា ។ (ប.ន.៧.១៦)

**សំណួរ:** **តើសកម្មភាពឃោសនាបោះឆ្នោតមានអ្វីខ្លះ ?**

**ចម្លើយ:** សកម្មភាពឃោសនាបោះឆ្នោត រួមមាន ÷

- -ការដង្ហែក្បួនដោយថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ។
- -ការជួបប្រជុំជាសាធារណៈ ។

-ការប្រគំតន្ត្រី ការលេងភ្លេង ឬការរាំកំសាន្ត ។

-ការសម្តែងរឿងល្ខោនខ្លីៗ ឬការសម្តែងសិល្បៈ ឬការបញ្ចាំងខ្សែភាពយន្ត ឬវីដេអូ ។

-ក្បួនព្យុហយាត្រា ។

-សកម្មភាពកីឡា ដើម្បីប្រមូលប្រាក់គាំទ្រគណបក្សនយោបាយណាមួយ និង/ឬ បេក្ខជនណាម្នាក់ ។

**សំណួរ:** **តើសកម្មភាពដែលមានន័យជ្រៀតជ្រែក ឬ/និងធ្វើឱ្យរំខាន ឬ ធ្វើឱ្យរាំងស្ទះនោះមានអ្វីខ្លះ ?**

**ចម្លើយ:** សកម្មភាពដែលមានន័យជ្រៀតជ្រែក ឬ/និងធ្វើឱ្យរំខាន ឬ ធ្វើឱ្យរាំងស្ទះនោះ រួមមាន÷

-ការនិយាយដៀមដាម ប្រមាថមើលងាយ ។

-ការធ្វើទុក្ខទោសដល់រាងកាយ ។

-ការវាយតប់លើរាងកាយនៃបុគ្គលណាម្នាក់ ។

-ការបាញ់កាំភ្លើងនៅនឹងកន្លែងដែលគណបក្សកំពុងធ្វើការឃោសនា ឬកន្លែងប្រជុំ ។

-ការរារាំងដោយមធ្យោបាយផ្សេងៗ ដើម្បីបន្ទុចបង្អាក់មិនឱ្យក្បួនដង្ហែការឃោសនាទៅមុខបាន ឬបញ្ឈប់សកម្មភាពឃោសនាផ្សេងៗទៀតរបស់គណបក្សនយោបាយ ។

-ការប្រើគ្រឿងផ្ទុះដើម្បីរំខានដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជន ។

-ការប្រើឧបករណ៍បំពងសម្លេងដើម្បីរំខានដល់ទីកន្លែង ដែលគណបក្សនយោបាយ ឬបេក្ខជនកំពុងធ្វើការឃោសនា ឬការជួបប្រជុំ ។

-ការទម្លាក់ស្លាក ឬបំផ្លាញបដាគណបក្ស ឬសម្ភារៈឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជន ។

-ការហាមឃាត់ ឬរារាំងប្រជាពលរដ្ឋមិនឱ្យចូលរួមក្នុងកិច្ចប្រជុំ ឬក្បួនដង្ហែរបស់គណបក្សនយោបាយណាមួយ ។